ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
អគ្គលេខាធិការដ្ឋាន

# ការគ្រប់គ្រងបុគ្គលិកពិសេសកាស៊ីណូ

ក្រុមការងារសិក្សា ស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងធនធានមនុស្សក្នុងវិស័យល្បែងពាណិជ្ជកម្ម

# មាតិកា

១. ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

២. និយមន័យបុគ្គលិកពិសេស

៣. ប្រភេទនៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

៤. ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូ

៥. លក្ខខណ្ឌ និងកាតព្វកិច្ចរបស់បុគ្គលិកពិសេស

៦.ទោសប្បញ្ញត្តិ

# ១. ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០
- អនុក្រឹត្យលេខ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ
- ប្រកាសលេខ ០០៥ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- ប្រកាសលេខ ០០៤ គ.ល.ក.ប្រក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលប្រការ ៦ នៃប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ នីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ
- សេចក្តីណែនាំលេខ ០០៥/២៣ អ.គ.ល.ក.សណន ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

# ២. និយមន័យបុគ្គលិកពិសេស

យោងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម៖

**មាត្រា ៤៦**

ចំពោះកាស៊ីណូ បុគ្គលិកពិសេសគឺជាបុគ្គលដែលបម្រើការក្នុងកាស៊ីណូនិងមានសមត្ថកិច្ចជាអ្នកគ្រប់គ្រងដែលមានសិទ្ធិធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការចាត់ចែងលើប្រតិបត្តិការកាស៊ីណូ ឬបុគ្គលិកដែលមានមុខងារ និងភារកិច្ចដូចខាងក្រោម៖

ក. ដំណើរការល្បែងក្នុងកាស៊ីណូ។

ខ. ការចរាចរសាច់ប្រាក់ឬកាក់ល្បែងនៅក្នុងបរិវេណកាស៊ីណូ។

គ. ការប្តូរប្រាក់ឬកាក់ល្បែងទៅឱ្យភ្ញៀវល្បែងនៅក្នុងកាស៊ីណូ។

ឃ. ការរាប់ប្រាក់ឬកាក់ល្បែងនៅក្នុងបរិវេណកាស៊ីណូ។

ង. ការរក្សាសុវត្ថិភាពនិងការតាមដានត្រួតពិនិត្យនៅក្នុងកាស៊ីណូ។

ច. ដំណើរការ ការថែរក្សា ការដំឡើង ឬជួសជុលតុល្បែង ម៉ាស៊ីនល្បែង ឬឧបករណ៍ល្បែងពាណិជ្ជកម្មដទៃទៀតនៅក្នុងកាស៊ីណូ។

ឆ. ការគ្រប់គ្រងនិងត្រួតពិនិត្យសកម្មភាពទាំងអស់ខាងលើ។

ជ. សកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងប្រតិបត្តិការកាស៊ីណូដែលកំណត់ដោយ **គ.ល.ក.** ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ប្រតិបត្តិករកាស៊ីណូ។

# ២. និយមន័យបុគ្គលិកពិសេស (ត)

យោងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម៖

## មាត្រា ៤៦

អ្នកកាន់កាប់អាជ្ញាបណ្ណបុគ្គលិកពិសេសម្នាក់ៗត្រូវអនុវត្តតែមុខងារដែលបានបញ្ជាក់នៅក្នុងអាជ្ញាបណ្ណបុគ្គលិកពិសេសរបស់ខ្លួនផ្ទាល់ប៉ុណ្ណោះ អនុលោមតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណបុគ្គលិកពិសេស។ ប្រតិបត្តិករល្បែងពាណិជ្ជកម្មត្រូវទទួលខុសត្រូវក្នុងការប្រើប្រាស់សេវារបស់និយោជិតខ្លួនអនុលោមតាមបទប្បញ្ញត្តិនេះ។

# ៣. ប្រភេទនៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ

ប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ៖

អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូបែងចែកជា ២ ប្រភេទ

ប្រការ ៤

១ អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ "ក"

២ អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ "ខ"

# ៣. ប្រភេទនៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ (ត)

ប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ៖

១

អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ "ក" សម្រាប់បុគ្គលិកដែលមានមុខតំណែងចាប់ពីអ្នកគ្រប់គ្រងឡើងទៅ មានដូចជា៖ ប្រធាន/អគ្គនាយក, នាយក, អគ្គទីប្រឹក្សា/ទីប្រឹក្សា, ជំនួយការប្រធាន/អគ្គនាយក ឬជំនួយការអ្នកកាន់កាប់អាជ្ញាបណ្ណកាស៊ីណូ និង/ឬប្រតិបត្តិករកាស៊ីណូ និងអ្នកគ្រប់គ្រង។

# ៣. ប្រភេទនៃអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ (ត)

ប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ៖

២

អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ប្រភេទ "ខ"សម្រាប់បុគ្គលិកដែលមានមុខតំណែងចាប់ពីអ្នកត្រួតពិនិត្យចុះទៅមានដូចជា៖ សវនកររបស់កាស៊ីណូ, គណនេយ្យកររកាស៊ីណូ, អ្នកត្រួតពិនិត្យ, ខ្សៀលល័រល្បែង, អ្នកប្រចាំការនៅស្លូតម៉ាស៊ីន, អ្នកប្រចាំការឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក, បុគ្គលិកទទួលភ្ញៀវល្បែងកាស៊ីណូ/ភ្ញៀវល្បែងវីអាយភី, អ្នកផ្តល់រង្វាន់ ឬពិន្ទុសម្រាប់ភ្ញៀវល្បែង, អ្នកគិតលុយនៅខេច, មែនបែងឃី, អ្នកកត់ត្រា ឬប្រមូលឥណទាន, អ្នកទទួលបន្ទុកទម្លាក់និងរាប់, បុគ្គលិកសន្តិសុខក្នុងកាស៊ីណូ, អ្នកប្រតិបត្តិការឧបករណ៍តាមដាន, អ្នកបច្ចេកទេសស្លូតម៉ាស៊ីន ឬឧបករណ៍ល្បែងមេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក, អ្នកបច្ចេកទេសសម្រាប់ឧបករណ៍តាមដានប្រព័ន្ធគ្រប់គ្រងស្លូតម៉ាស៊ីន ឬឧបករណ៍ល្បែង មេកានិក អេឡិចត្រូមេកានិក ឬអេឡិចត្រូនិក។

# ៤. ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូ

ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូត្រូវបានបែងចែកចេញជា ២ដំណាក់កាលៈ

១ មុនពេលផ្តល់អាជ្ញាបណ្ណ

២ ក្រោយពេលផ្តល់អាជ្ញាបណ្ណ

# ៤. ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូ (ត)

ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូត្រូវបានបែងចែកចេញជា ២ដំណាក់កាល៖

១

## មុនពេលផ្តល់អាជ្ញាបណ្ណ

លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដែលបុគ្គលិកពិសេសកាស៊ីណូត្រូវបំពេញ គឺមានសមត្ថភាព និងចំណេះដឹងគ្រប់គ្រាន់ដើម្បីអនុវត្តមុខងាររបស់ខ្លួនក្នុងនាមជាបុគ្គលិកពិសេស។

បច្ចុប្បន្ន ឯកសារបញ្ជាក់ពីសមត្ថភាពមុខងារដែលត្រូវអនុវត្តនៅក្នុងអាជ្ញាបណ្ណអាចបញ្ជាក់បានដោយប្រតិបត្តិករកាស៊ីណូ ប៉ុន្តែនាពេលអនាគត មុនពេលស្នើសុំអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ បុគ្គលិកទាំងនោះនឹងត្រូវទទួលការបណ្តុះបណ្តាលពី **អ.គ.ល.ក.** និងចូលរួមប្រឡងទទួលស្គាល់គុណវុឌ្ឍិ ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពពី **អ.គ.ល.ក.**។

# ៤. ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាសុីណូ (ត)

ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាសុីណូត្រូវបានបែងចែកចេញជា ២ដំណាក់កាល៖

២

## ក្រោយពេលផ្តល់អាជ្ញាបណ្ណ

ក្នុងគោលបំណងធានាបានថាបុគ្គលិកពិសេសកាសុីណូរក្សាបាននូវគុណវុឌ្ឍិរបស់ខ្លួនក្រោយទទួលបានអាជ្ញាបណ្ណបុគ្គលិកពិសេស ព្រមទាំងទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមដើម្បីបំពេញមុខងាររបស់ខ្លួន **អ.គ.ល.ក.** នឹងមានរៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗទៀតជូនដល់បុគ្គលិកពិសេស ក្នុងរយៈពេលកំណត់ដោយ **អ.គ.ល.ក.**

# ៤. ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូ (ត)

ការគ្រប់គ្រងគុណវុឌ្ឍិរបស់បុគ្គលិកពិសេសកាស៊ីណូត្រូវបានបែងចែកចេញជា ២ដំណាក់កាល៖

២

## ក្រោយពេលផ្តល់អាជ្ញាបណ្ណ

យោងតាមប្រកាស ៥ នៃប្រកាសលេខ ០០៦ គ.ល.ក.ប្រក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ អាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូមានសុពលភាពមិនលើសពី ៣ ឆ្នាំ ហើយត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមុនពេលអាជ្ញាបណ្ណផុតសុពលភាព

ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូ ក៏តម្រូវឱ្យមានឯកសារបញ្ជាក់ពីសមត្ថភាពមុខងារដែលត្រូវអនុវត្តនៅក្នុងអាជ្ញាបណ្ណផងដែរ ដូច្នេះ មុនពេលអាចបន្តសុពលភាពអាជ្ញាបណ្ណបុគ្គលិកពិសេសកាស៊ីណូបាន បុគ្គលិកទាំងអស់ត្រូវចូលរៀនវគ្គរំលឹកឡើងវិញ (refreshing course) និងត្រូវប្រឡងទទួលស្គាល់គុណវុឌ្ឍិសារជាថ្មី ដើម្បីទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពពី **អ.គ.ល.ក.** ម្តងទៀត។

# ៥. លក្ខខណ្ឌ និងភាតព្វកិច្ចរបស់បុគ្គលិកពិសេស

យោងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

- បុគ្គលិកពិសេសរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មមួយ មិនអាចជាភាគហ៊ុនិកមានគុណវុឌ្ឍិឬជាបុគ្គលិកពិសេសរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មផ្សេងទៀត ឬរបស់កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ ឬរបស់អ្នកគ្រប់គ្រងកាស៊ីណូ ឬរបស់ភាគីពាក់ព័ន្ធណាមួយដោយផ្ទាល់ ឬដោយប្រយោលឡើយ។
- បុគ្គលិកពិសេសរបស់ប្រតិបត្តិករកាស៊ីណូនិងកម្មករនិយោជិតរបស់កាស៊ីណូ ក្នុងពេលតែមួយ មិនមែនជាមន្ត្រីរាជការ ឬមន្ត្រី **គ.ល.ក.**។
- ការចូលលេងល្បែងនៅក្នុងកាស៊ីណូឬគ្រឹះស្ថានល្បែងពាណិជ្ជកម្ម ត្រូវបានហាមឃាត់ចំពោះកម្មករនិយោជិតរបស់ប្រតិបត្តិករកាស៊ីណូឬប្រតិបត្តិករល្បែងពាណិជ្ជកម្មនៃគ្រឹះស្ថានល្បែងពាណិជ្ជកម្មដែលពួកគេកំពុងបម្រើការនៅទីនោះ។
- ការដំណើរការល្បែងណាមួយនៅក្នុងគ្រឹះស្ថានល្បែងពាណិជ្ជកម្មលុះត្រាតែល្បែងនោះត្រូវបានដំណើរការដោយបុគ្គលិកពិសេសដែលមានអាជ្ញាបណ្ណ។

# ៦. ទោសប្បញ្ញត្តិ

អនុក្រឹត្យលេខ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្ដីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

| | |
|---|---|
| ចំណុច "ង" នៃមាត្រា៤ | ៖ ការបន្តអនុវត្តមុខងារជាបុគ្គលិកពិសេសក្រោមអាជ្ញាបណ្ណផុតសុពលភាព។ |
| ចំណុច "គ" នៃមាត្រា៦ | ៖ ធ្វើប្រតិបត្តិការជាបុគ្គលិកពិសេសដោយគ្មានអាជ្ញាបណ្ណ។ |
| ចំណុច "ង" នៃមាត្រា៧ | ៖ មិនចាប់ផ្តើមការងារក្នុងរយៈពេលកំណត់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រោយទទួលបានអាជ្ញាបណ្ណពី **គ.ល.ក.** |
| ចំណុច "ង" នៃមាត្រា៨ | ៖ ការបន្តអនុវត្តមុខងារជាបុគ្គលិកពិសេសក្នុងពេលអាជ្ញាបណ្ណត្រូវបានព្យួរ ឬដកហូត |
| មាត្រា ១៦ | ៖ ពុំអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៥៨ នៃច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដែលក្នុងនោះមានចំណុច (ឃ) គឺ "ធានាថាបុគ្គលិកពិសេសរបស់ប្រតិបត្តិករកាស៊ីណូនិងកម្មករនិយោជិតរបស់កាស៊ីណូ ក្នុងពេលតែមួយ មិនមែនជាមន្ត្រីរាជការ ឬមន្ត្រី **គ.ល.ក.**" |
| ចំណុច "ង" នៃមាត្រា២៨ | ៖ ខកខានក្នុងការបង់កម្រៃអាជ្ញាបណ្ណប្រចាំឆ្នាំតាមការកំណត់របស់ **គ.ល.ក.** |

# ៦. ទោសប្បញ្ញត្តិ ( ឥ )

អនុក្រឹត្យលេខ១០២ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្ដីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសទៅនឹងច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

| | |
|---|---|
| មាត្រា ២៩ | ៖ ពុំអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី២ មាត្រា៥៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម "បុគ្គលិកពិសេសរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មមួយ មិនអាចជាភាគហ៊ុនិកមានគុណវុឌ្ឍិឬជាបុគ្គលិកពិសេសរបស់ប្រតិបត្តិករល្បែងពាណិជ្ជកម្មផ្សេងទៀត ឬរបស់កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ឬកម្មសិទ្ធិករកាស៊ីណូ ឬរបស់អ្នកគ្រប់គ្រងកាស៊ីណូ ឬរបស់ភាគីពាក់ព័ន្ធណាមួយដោយផ្ទាល់ ឬដោយប្រយោលឡើយ" |

# សូមអរគុណ